# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ.......................... ស.ខ.ក.ក.

# សេចក្តីថ្លែងការណ៍

## ឯកឧត្តមថាច់ សេដ្ឋា អតីតសមាជិកព្រឹទ្ធសភា

### នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម ក្នុងខួបគំរប់៦០ឆ្នាំនៃទិវាសិទ្ធិមនុស្សអន្តរជាតិ

### ១០-១២-១៩៤៨ - ១០-១២-២០០៨

សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ

សូមគោរពបងប្អូនជនរួមជាតិ ជាទីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត

វត្តមានរបស់ព្រះតេជគុណគ្រប់ព្រះអង្គ បងប្អូនជនរួមឈាមខ្មែរកំណើតកម្ពុជាក្រោមនាពេលនេះគឺតំណាងប្រជារាស្ត្រខ្មែរទាំងអស់ដែលកំពុងរស់នៅលើទឹកដីកម្ពុជាក្រោម ដើម្បីប្រារព្ធពិធីអបអរសាទរខួបគំរប់៦០ឆ្នាំ នៃទិវាសិទ្ធិមនុស្សអន្តរជាតិជាមួយមនុស្សជាតិនៅលើសកលលោក ទោះបីប្រជារាស្ត្រខ្មែរកម្ពុជាក្រោមពុំដែលទទួលបានផលប្រយោជន៍សិទ្ធិមនុស្ស១០ធ្នូក្នុងរយៈពេល៦០ឆ្នាំកន្លងមកនេះឬពុំដែលស្គាល់អ្វីទៅហៅថាសិទ្ធិមនុស្សក៏ដោយ។

ទន្ទឹមនិងប្រជាជាតិនានានៅលើសកលលោកកំពុងតែប្រារព្ធពិធីអបអរសាទរទិវាសិទ្ធិមនុស្សយ៉ាងសប្បាយរីករាយ ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមជាង១៣លាននាក់ កំពុងទទួលរងការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរពីអាជ្ញាធរអាណានិគមវៀតណាមនៅលើទឹកដីកំណើតរបស់ខ្លួន បច្ចុប្បន្នសាធារណរដ្ឋសង្គមនិយមវៀតណាម ប៉ែកខាងត្បូង។ កាលណានិយាយដល់ការរំលោភសិទ្ធិមនុស្សនៅលើសកលលោក មិនត្រូវនិយាយរំលងអំពីការរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសវៀតណាមទេ ជាពិសេសខ្មែកម្ពុជាក្រោម។ ៦០ឆ្នាំបានកន្លងផុត សិទ្ធិជាមូលដ្ឋានរបស់មនុស្សត្រូវបានអាជ្ញាធរអាណានិគមវៀតណាមកាត់ផ្តាច់ពីប្រជារាស្ត្រខ្មែរកម្ពុជាក្រោមយ៉ាងព្រហើនបំផុត ដោយគ្មានកោតក្រែងនរណាឡើយ មិនតែប៉ុណ្ណោះអាជ្ញាធរអាណានិគមវៀតណាមបានប្រើល្បិចកលដ៏មានប្រសិទ្ធភាពក្នុងការបិទបាំងអំពើអាក្រក់លាមករបស់ខ្លួន មិនខុសពីរបបកម្ពុជាប្រជាធិបតេយ្យរបស់ពួកប៉ុល ពតទេ។ ការរស់នៅរបស់ប្រជារាស្ត្រខ្មែកម្ពុជាក្រោម គ្រាន់តែសំរាប់ទទួលរងទារុណកម្មផ្សេងៗ ពីអាជ្ញាធរអាណានិគមវៀតណាមរង់ចាំថ្ងៃស្លាប់ទៅវិញតែប៉ុណ្ណោះ។

ការជួបជុំរបស់យើងទាំងអស់គ្នាដែលជាមនុស្សខ្មែរកំណើតកម្ពុជាក្រោមក្នុងឱកាសដ៏វិសេសវិសាលនេះគឺជាសារមួយជូនសហគមន៍អន្តរជាតិ ជាពិសេសអង្គការសហប្រជាជាតិ និងបណ្តាប្រទេសស្រឡាញ់យុត្តិធម៌និងការពារសិទ្ធិមនុស្សមេត្តាជ្រាបថា ទោះបីបច្ចុប្បន្ននេះ ប្រជាជាតិនានានៅលើសកលលោកកំពុងទទួលបានសិទ្ធិសេរីភាពយ៉ាងល្អប្រសើរ និងទទួលបានកិច្ចការពារផ្នែកសិទ្ធិមនុស្សយ៉ាកក់ក្តៅពីសហគមន៍អន្តរជាតិយ៉ាងណាក៏

ភូមិគ្រឹះលេខ៩៦ , ផ្លូវ៣៧១ , ភូមិត្រពាំងឈូក , សង្កាត់ទឹកថ្លា , ខណ្ឌឫស្សីកែវ , រាជធានីភ្នំពេញ
ទូរស័ព្ទ-ទូរសារលេខ : (៨៥៥) ២៣ ៩៩៥ ៥៨១, ១២ ៨៥១ ៩៥១ / ៩០ ៨៨ ៨២.
អ៊ីមែល: kkcommunity@camintel.com or k.k.k.c@camitel.com; website: http://khmerkromngo.org

ដោយ តែប្រជារាស្ត្រខ្មែរកម្ពុជាក្រោមបែរជាកំពុងទទួលការរំលោភសិទ្ធិមនុស្សយ៉ាងព្រៃផ្សៃពីអាជ្ញាធរអាណានិគមវៀតណាមទៅវិញ។ ក្រៅពីចាប់ព្រះសង្ឃ និងប្រជារាស្ត្រខ្មែរធ្វើទារុណកម្មយ៉ាងឃោរឃៅរហូតដល់បាត់បង់ជីវិតរាប់រយនាក់ និងដាក់ពន្ធនាគារចំនួន៤២៤៨នាក់នៅឆ្នាំ១៩៨៥-១៩៨៧នោះមក បច្ចុប្បន្ន ប្រទេសកុម្មុយនិស្តដ៏ផ្តាច់ការមួយនេះ នៅតែបន្តការគាបសង្កត់រិតបន្តឹងសិទ្ធិសេរីភាពទាំងផ្លូវចិត្តទាំងផ្លូវកាយមកលើប្រជារាស្ត្រខ្មែរជារៀងដរាប ក្នុងនោះមានសិទ្ធិក្នុងផ្នែកជំនឿសាសនា សិទ្ធិនយោបាយ សិទ្ធិបង្កើតអង្គការ-សមាគម សិទ្ធិសេដ្ឋកិច្ច សិទ្ធិសិក្សារៀនសូត្រ សិទ្ធិសម្តែងមតិ សិទ្ធិទទួលពត៌មាន និងផ្សព្វផ្សាយពត៌មានជាដើម។

**១-សិទ្ធិជំនឿសាសនា** ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម៩៩%គោរពព្រះពុទ្ធសាសនា។ បច្ចុប្បន្នព្រះពុទ្ធសាសនាខ្មែរត្រូវស្ថិតក្រោមការត្រួតត្រារបស់បក្សកុម្មុយនិស្តវៀតណាមយ៉ាងតឹងរ៉ឹងបំផុត ដោយមិនអនុញ្ញាតធ្វើសកម្មភាពដោយឯករាជ្យឡើយ។ ការសិក្សារៀនសូត្ររបស់ព្រះសង្ឃត្រូវអនុវត្តតាមមនោគមវិជ្ជាកុម្មុយនិស្តជាដាច់ខាត់ ការតវ៉ាផ្សេងៗត្រូវចាប់ផ្សឹកដាក់ពន្ធនាគារ ចាប់បង្ខំព្រះសង្ឃគ្រប់វត្តអារាមឲ្យចិញ្ចឹមសត្វពាហនៈ និងធ្វើពលកម្មដូចគ្រហស្ថ ដែលជាការប្រាស់ចាកនឹងធម៌វិន័យព្រះពុទ្ធសាសនា តាមវត្តអារាមនានាត្រូវបង្ខំឲ្យបង់វិភាគទានជូនរដ្ឋ។ល។

**២-សិទ្ធិនយោបាយ** ប្រជារាស្ត្រខ្មែរមិនអាចនិយាយបញ្ហានយោបាយប្រទេសជាតិរបស់ខ្លួនបានជាដាច់ខាត់ សូម្បីតែរំលឹកប្រវត្តិរឿងរ៉ាវទឹកដីកម្ពុជាក្រោមក៏ត្រូវជាប់ពន្ធនាគារដែរ។

**៣-សិទ្ធិបង្កើតអង្គការ-សមាគម** អាជ្ញាធរអាណានិគមវៀតណាម មិនអនុញ្ញាតឲ្យមានការបង្កើតអង្គការសមាគម ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់សហគមន៍ខ្មែរកម្ពុជាក្រោម ដែលជាជនជាតិដើមទឹកដីនៅទីនោះឡើយ។ រីឯសមាគមព្រះសង្ឃខ្មែរបច្ចុប្បន្ន អាជ្ញាធរអាណានិគមវៀតណាមជាអ្នកបង្កើតឡើង ដើម្បីងាយស្រួលក្នុងការត្រួតត្រាព្រះសង្ឃខ្មែរតែប៉ុណ្ណោះ។

**៤-សិទ្ធិសេដ្ឋកិច្ច** ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម៩៥%ជាកសិករ។ ដីស្រែរបស់កសិករខ្មែរដែលជាម្ចាស់ដើមទឹកដីមួយចំនួនត្រូវបានអាជ្ញាធរអាណានិគមវៀតណាមរឹបអូស ដែលជាហេតុធ្វើឲ្យប្រជារាស្ត្រខ្មែរភាគច្រើនគ្មានដីស្រែសំរាប់ធ្វើកសិកម្ម ធ្លាក់ខ្លួនក្របង្ខំចិត្តចាកចោលផ្ទះសម្បែងទៅស៊ីឈ្នួលជនជាតិវៀតណាម តាមបណ្តាខេត្តនានាយ៉ាងវេទនាជាទីបំផុត។

**៥-សិទ្ធិក្នុងការសិក្សារៀនសូត្រអក្សរសាស្ត្រខ្មែរ** សាលារៀនអក្សរសាស្ត្រខ្មែរមាននៅតាមវត្តអារាមបន្តិចបន្តួច ដើម្បីបំភាន់សាធារណមតិជាតិ អន្តរជាតិតែប៉ុណ្ណោះ។ ការសិក្សារៀនសូត្រត្រូវហាមឃាត់មិនឲ្យរៀនមុខវិជ្ជាភូមិសាស្ត្រ ប្រវត្តិសាស្ត្រជាដាច់ខាត់ គ្រូបង្រៀន កូនសិស្ស ស្ថិតក្រោមការឃ្លាំមើលយ៉ាងជិតដល់ពីអាជ្ញាធរវៀតណាម បើហាននិយាយពីប្រវត្តិសាស្ត្រ ភូមិសាស្ត្រឬអំពីរឿងនយោបាយត្រូវជាប់ពន្ធនាគារដោយមិនអាចប្រកែកបាន។

**៦-សិទ្ធិក្នុងការសម្តែងមតិ** ទាំងព្រះសង្ឃទាំងគ្រហស្ថមិនអាចប្រមូលផ្តុំប្រជុំគ្នាធ្វើបាតុកម្មប្រឆាំងតវ៉ា ឬទាមទាអ្វីមួយបានឡើយ ទោះក្នុងរូបភាពណាក៏ដោយ។

**៧-សិទ្ធិទទួលពត៌មាន និងផ្សព្វផ្សាយពត៌មាន** ហាមប្រើប្រាសអ៊ីនធើណែតឬអ៊ីម៉ែលឆ្លើយឆ្លងមកក្រៅប្រទេស ស្តាប់វិទ្យុសម្លេងសហរដ្ឋអាមេរិក ឬអាស៊ីសេរីជាដើម។ ចំណែកកាសែតជាភាសាខ្មែរគឺគ្មានតែម្តង រីឯទស្សនវដ្តី វិទ្យុ ទូរទស្សន៍ដែលមានតិចបំផុតនោះគឺ ស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យយ៉ាងហ្មត់ចត់

THE KHMER KAMPUCHEA KROM COMMUNITY

បំផុតពីអាជ្ញាធរវៀតណាមមុននិងចេញផ្សាយ។

បពិត្រព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ !

បងប្អូនរមណាមជាទីស្នេហា !

តាមរយៈអង្គមេទ្ធិញដ៏មហោឡារិកថ្ងៃនេះ ក្នុងនាមប្រជារាស្ត្រខ្មែរ ដែលជាជនរងគ្រោះពីការរំលោភសិទ្ធិមនុស្សទាំងអស់ សូមអំពាវនាវយ៉ាងទទូចដល់រាជរដ្ឋាភិបាលកម្ពុជា មេត្តាអនុញ្ញាតឲ្យយើងខ្ញុំ ប្រជារាស្ត្រខ្មែរកំណើតកម្ពុជាក្រោម បានប្រមូលផ្តុំប្រជុំគ្នាធ្វើជាមេទ្ធិញទីសាធារណៈ ឬដង្ហែរជាក្បួនបាតុកម្ម ដើម្បីសម្តែងមតិប្រឆាំង តវ៉ាឬទាមទាអ្វីមួយ និងអនុវត្តតួនាទីរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការការពារប្រជាពលរដ្ឋខ្មែរនៅបរទេស ជាពិសេសប្រជាពលរដ្ឋខ្មែរនៅកម្ពុជាក្រោម បច្ចុប្បន្នសាធារណរដ្ឋសង្គមនិយមវៀតណាម និងបើកការសើបអង្កេតឡើងវិញករណីឃាដកម្មយ៉ាងអាថ៌កំបាំងមកលើព្រះតេជគុណអ៊ាង សុខធឿន នៅវត្តទ្រនំជ្រើង ក្នុងស្រុកអង្គស្នួល ខេត្តកណ្តាលកាលពីឆ្នាំ២០០៧។

តាមរយៈអង្គមេទ្ធិញនេះដែរ យើងខ្ញុំសូមអំពាវនាវដល់អង្គការអន្តរជាតិ និងបណ្តាប្រទេសនានា ដែលលើកស្ទួយសិទ្ធិមនុស្ស ជាពិសេសអង្គការសហប្រជាជាតិ មេត្តាពិនិត្យឡើងវិញចំពោះការអនុវត្តបណ្តាប្រទេសជាភាគីហត្ថលេខីដែលបានផ្តល់សច្ចាប័ណ្ណគាំទ្រសេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្សក្នុងរយៈ៦០ឆ្នាំកន្លងមកនេះ បានអនុវត្តត្រឹមត្រូវស្របតាមសេចក្តីថ្លែងការណ៍ កតិកាសញ្ញា អនុសញ្ញានិងបទដ្ឋាននានាស្តីអំពីសិទ្ធិមនុស្សជាអន្តរជាតិហើយឬនៅ។ ក្នុងករណីរដ្ឋាភិបាលនៃប្រទេសណាមួយពុំព្រមអនុវត្ត ឬបានបង្កើនការរំលោភសិទ្ធិមនុស្ស កាន់តែធ្ងន់ធ្ងរថែមទៀត សូមមេត្តាប្រើប្រាស់គ្រប់មធ្យោបាយជំរុញរដ្ឋាភិបាលនៃប្រទេសទាំងនោះអោយអនុវត្តខាងតែបាន ក្នុងនោះមានសាធារណរដ្ឋសង្គមនិយមវៀតណាមផងដែរ។

ម្យ៉ាងទៀត យើងខ្ញុំសូមអំពាវនាវដល់អង្គការសហប្រជាជាតិ សូមមេត្តាៈ

១-បើកទីស្នាក់ការឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីតាមដានរាល់ការរំលោភសិទ្ធិមនុស្សនានាពីសំណាក់រដ្ឋាភិបាលវៀតណាមមកលើប្រជារាស្ត្ររបស់ខ្លួន ជាពិសេសប្រជារាស្ត្រខ្មែរ។

២-ចាត់វិធានការដ៏មុឺងម៉ាត់ ជំរុញរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ឲ្យគោរពសិទ្ធិមនុស្សសិទ្ធិជំនឿសាសនា សិទ្ធិជនជាតិដើមឲ្យបានពេញលេញស្របតាមសេចក្តីថ្លែងការណ៍ កតិកាសញ្ញា អនុសញ្ញានិងបទដ្ឋាននានាស្តីអំពីសិទ្ធិមនុស្សជាអន្តរជាតិ។

៣-ជំរុញរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ឲ្យដោះលែងព្រះសង្ឃពុទ្ធសាសនាចំនួន៥អង្គដែលអាជ្ញាធរវៀតណាមបានចាប់ផ្សឹកនិងកំពុងឃុំឃាំងនៅពន្ធនាគារខេត្តឃ្លាំង(សុក ត្រាំង) និងបញ្ជូនព្រះតេជគុណទឹម សាខនមកកម្ពុជាជួបជុំគ្រួសារដោយឥតលក្ខខណ្ឌ។

៤-ជំរុញរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម បញ្ឈប់ជាបន្ទាន់នូវរាល់ការរឹបអូសយកដីធ្លីពីសសហគមន៍ខ្មែរកម្ពុជាក្រោម។

៥-ជំរុញរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមបញ្ឈប់ជាបន្ទាន់នូវរាល់ការចាប់បង្ខំឲ្យវត្តអារាមព្រះពុទ្ធសាសនាខ្មែរបង់វិភាគទានជូនរដ្ឋ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្នុងនាមប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណ

THE KHMER KAMPUCHEA KROM COMMUNITY

យ៉ាងជ្រាលជ្រៅបំផុតចំពោះឯកឧត្តមប្រធាន អនុប្រធាន និងសមាជិក សមាជិកានៃសភាសហគមន៍អឺរ៉ុបដែលបានបោះឆ្នោតគាំទ្រលើសេចក្តីសំរេចជាប្រវត្តិសាស្ត្រមួយកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៨ក្នុងការបង្ខំឲ្យរដ្ឋាភិបាលវៀតណាមគោរពសិទ្ធិមនុស្ស និងសិទ្ធិជំនឿសាសនាឲ្យបានត្រឹមត្រូវស្របតាមបទដ្ឋានអន្តរជាតិ។ នេះជាសេចក្តីសំរេចប្រកបដោយគតិបណ្ឌិត ហើយបានឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់ចំពោះអំពើមនុស្សធម៌ និងការការពារសិទ្ធិមនុស្សដល់ប្រជារាស្ត្រទន់ខ្សោយក្នុងសកលលោកយ៉ាងពិតប្រាកដ។ចាប់តាំងពីអាណានិគមបារាំងបានកាត់ទឹកដីកម្ពុជាក្រោមឲ្យអាណានិគមវៀតណាមត្រួតត្រារហូតសព្វថ្ងៃ តាមច្បាប់បារាំងលេខ៤៩-៧៣៣ចុះថ្ងៃទី០៤ខែមិថុនា ឆ្នាំ១៩៤៩មក ពុំដែលមានអង្គការអន្តរជាតិណាមួយចាប់អារម្មណ៍ចំពោះការឈឺចាប់និងសេចក្តីទុក្ខវេទនារបស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមឡើយ។ អាជ្ញាធរវៀតណាម ពីរបបមួយទៅរបបមួយតែងតែអនុវត្តនយោបាយវៀតណាមូបនីយកម្មចំពោះប្រជារាស្ត្រខ្មែរឥតឈប់ឈរ អត្តសញ្ញាណនៃពូជសាសន៍ខ្មែរស្ទើរតែបាត់ម្តងៗ។ ដូចនេះទើបយើងខ្ញុំចាត់ទុកថា សេចក្តីសំរេចរបស់សភាសហគមអឺរ៉ុបជាប្រវត្តិសាស្ត្រសំរាប់យើងខ្ញុំ។ ជាមួយគ្នានេះដែរ យើងខ្ញុំមានជំនឿជឿជាក់ថា សភាសហគមន៍អឺរ៉ុបនឹងជំរុញសេចក្តីសំរេចនេះឲ្យមានប្រសិទ្ធភាពបំផុត ដើម្បីលើកស្ទួយវិស័យសិទ្ធិមនុស្ស និងជំនឿសាសនាឲ្យបានប្រសើរឡើងនៅប្រទេសវៀតណាម។

ទីបញ្ចប់ ខ្ញុំសូមឧទ្ទិសទិវាសិទ្ធិមនុស្សឆ្នាំនេះ ជូនមនុស្សជាតិទាំងអស់ក្នុងលោក ជាពិសេសប្រជារាស្ត្រខ្មែរកម្ពុជាក្រោមទទួលបានសិទ្ធិសេរីភាពពេញលេញ និងសូមប្រគេនពរនិងជូនពរដល់អង្គពិធីទាំងមូលបានប្រកបទៅដោយពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

សូមអរព្រះគុណនិងសូមអរគុណ !

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៨